# I- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យ ២០ អនក្រ.បក
### ស្តីពី
### ការធ្វើវិសោធនកម្ម លើអនុក្រឹត្យលេខ ៧៨ អនក្រ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការ ដឹកនាំការងារ នៃកម្មវិធីសិលា

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-អនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ៧៨អនក្រ ចុះថ្ងៃទី២៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា

**សម្រេច**

**មាត្រា ១ .-**

មាត្រា៣ ( ស្តីពីសមាសភាពគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ) នៃអនុក្រឹត្យ លេខ ៧៨ អនក្រ ចុះថ្ងៃទី២៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការ ដឹកនាំការងារ នៃកម្មវិធី សិលា ត្រូវបានកែប្រែដូចខាងក្រោមនេះ ៖

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២-រដ្ឋមន្ត្រីក្រសួង ធនធានទឹក និងឧតុនិយម | អនុប្រធាន |
| ៣-រដ្ឋលេខាធិការក្រសួង អភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៤-រដ្ឋលេខាធិការក្រសួង ផែនការ | សមាជិក |

៥-អនុរដ្ឋលេខាធិការក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ — សមាជិក

៦-អនុរដ្ឋលេខាធិការក្រសួង កិច្ចការនារី និងអតីតយុទ្ធជន — សមាជិក

៧-អគ្គនាយកផ្នែករដ្ឋបាល នៃក្រសួងមហាផ្ទៃ — សមាជិក

៨-អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាអគ្គលេខាធិការ
នៃគណៈកម្មាធិការទីតិសម្បទា និងអភិវឌ្ឍន៍ — អគ្គលេខាធិការ

**មាត្រា ២ .-**

រាល់បទបញ្ញត្តិណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-**

រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ និងសមាជិកដូចមានចែងក្នុងមាត្រា១ និងអភិបាលខេត្ត-ក្រុង ត្រូវអនុវត្តតាមអនុក្រឹត្យនេះដោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

បានជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី
ហត្ថលេខា
គាត ឈន់
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
ប្រធានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិរលោ

★★★

## អនុក្រឹត្យ ២១ អនក្រ.បក
## ស្តីពី ការបង្កើតគណៈកម្មាធិការជាតិទាំង ៦
## សំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកជំនាញ
## (Functional Cooperation)

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា